**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS

# កម្មវិធីអភិវឌ្ឍន៍សមត្ថភាពមន្ត្រីវ័យក្មេងក្រសួងនិងមន្ទីរកិច្ចការនារី ស្តីពីការប្រើប្រាស់ប្រព័ន្ធឌីជីថល ក្នុងការបំពេញការងារប្រចាំថ្ងៃ និងការនិយាយជាសាធារណៈតាមប្រព័ន្ធអនឡាញ

## I. សាវតា

ការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលម្នាក់ៗ គឺជាតម្រូវការចាំបាច់ និងមិនអាចខ្វះបានសម្រាប់គ្រប់បរិបទនិងទិដ្ឋភាពរបស់សង្គម និងដែលជាផ្នែកដ៏សំខាន់នៃការសិក្សាពេញមួយជីវិត។ ការអភិវឌ្ឍធនធានមនុស្ស ក្រៅពីជំនាញរឹង ត្រូវការជំនាញទន់ជាចាំបាច់ ដែលក្នុងនោះរួមមានជំនាញប្រាស្រ័យទាក់ទង និយាយជាសាធារណៈ ភាពបត់បែននិងច្នៃប្រឌិតជាដើម រួមទាំងចំណេះដឹងផ្នែកបច្ចេកវិទ្យា ដែលអាចសម្របខ្លួននិងឆ្លើយតបនឹងយុគសម័យឌីជីថល ។

ក្រសួងកិច្ចការនារី បានចាត់ទុកការអភិវឌ្ឍសមត្ថភាពស្ថាប័ន គឺជាកត្តាចាំបាច់ក្នុងការអនុវត្តយុទ្ធសាស្ត្រអាទិភាពនានានៃផែនការយុទ្ធសាស្ត្រ**នារីរតនៈទី៥** ប្រកបដោយជោគជ័យនិងប្រសិទ្ធភាព។ អភិក្រមនៃការអភិវឌ្ឍសមត្ថភាពស្ថាប័ននេះ តម្រូវឱ្យធ្វើឡើងតាមរយៈការឆ្លុះបញ្ចាំង និងឆ្លើយតបនឹងការប្រែប្រួលនៃការវិវត្តន៍និងបរិបទថ្មីៗរបស់សង្គមនិងជាសកល ក៏ដូចជាក្នុងបដិវត្តន៍ឧស្សាហកម្ម ទី៤ និងការធ្វើឌីជីថលភាវូបនីយកម្ម ។ ក្នុងន័យនេះ ក្រសួងកិច្ចការនារី បាននិងកំពុងផ្តោតលើការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងគាំទ្រដល់មន្ត្រីវ័យក្មេងជាប្រចាំ តាមរយៈកម្មវិធីរយៈពេលវែង មធ្យម និងខ្លី ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិលើជំនាញបច្ចេកទេសពាក់ព័ន្ធនឹងការបញ្ជ្រាបយេនឌ័រតាមវិស័យ និងស្របតាមបរិបទសង្គម រួមទាំងជំនាញទន់និងភាពជាអ្នកដឹកនាំ ជាពិសេសជំនាញសម្របសម្រួល ការនិយាយជាសាធារណៈ និងការប្រាស្រ័យទាក់ទងជាដើម ក្នុងគោលដៅប្រែក្លាយមន្ត្រីក្រសួងនិងមន្ទីរកិច្ចការនារី ឱ្យទៅជាអ្នកឯកទេសវិភាគយេនឌ័រ និងស្វែងរកការគាំទ្រមតិលើបញ្ហាយេនឌ័រនៅតាមវិស័យនីមួយៗ។

ជាមួយគ្នានេះ តាមរយៈនៃការរីកចម្រើនរបស់យុគសម័យឌីជីថល និងជាពិសេសឆ្លើយតបនឹងបរិការណ៍នៃការរីករាលដាលជំងឺកូវីដ-១៩ ដែលកំពុងកើតមានជាសកល ក៏ដូចជាប្រទេសកម្ពុជា បានតម្រូវឱ្យប្រជាជនជាទូទៅ ក៏ដូចជាអ្នកបម្រើសេវាសាធារណៈនិងឯកជន ត្រូវធ្វើការផ្លាស់ប្តូរពីរបៀបនៃការរស់នៅ ការប្រាស្រ័យទាក់ទងនិងការធ្វើការងារតាមបែបទស្សនទានគន្លងថ្មី ដែលក្នុងនោះតម្រូវការអាទិភាពនិងជាចាំបាច់មួយ គឺការប្រើប្រាស់តាមប្រព័ន្ធបច្ចេកវិទ្យានិងអនឡាញ ។

ក្នុងន័យខាងលើនេះ ក្រសួងកិច្ចការនារី គ្រោងនឹងរៀបចំកម្មវិធី**អភិវឌ្ឍន៍សមត្ថភាពមន្ត្រីវ័យក្មេងក្រសួងនិងមន្ទីរកិច្ចការនារី ស្តីពីការប្រើប្រាស់ប្រព័ន្ធឌីជីថល ក្នុងការបំពេញការងារប្រចាំថ្ងៃ និងជំនាញក្នុងការនិយាយជាសាធារណៈតាមប្រព័ន្ធអនឡាញ** ក្នុងគោលដៅដើម្បីពង្រីកសក្តានុពល និងភាពសកម្មរបស់មន្ត្រីវ័យក្មេងក្រសួងនិងមន្ទីរកិច្ចការនារី ក្នុងការចូលរួមអនុវត្តន៍ការងាររបស់ស្ថាប័ន ក៏ដូចជាការងារលើកកម្ពស់សមភាពយេនឌ័រនិងបង្កើនភាពអង់អាចដល់ស្ត្រី តាមរយៈការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល និងអនឡាញ ។

## II. គោលបំណង

- បង្កើនចំណេះដឹង និងសមត្ថភាពផ្នែកឌីជីថលរបស់មន្ត្រីវ័យក្មេងរបស់ក្រសួង និងមន្ទីរកិច្ចការនារី ដើម្បីប្រើប្រាស់សម្រាប់ការប្រាស្រ័យទាក់ទង និងបំពេញការងារប្រចាំថ្ងៃ រួមទាំងរបៀបនៃការរៀបចំនិងដំណើរការកិច្ចប្រជុំ សិក្ខាសាលា និងព្រឹត្តិការណ៍នានាតាមប្រព័ន្ធអនឡាញ ។
- អភិវឌ្ឍន៍ជំនាញស្តីពីការនិយាយជាសាធារណៈនិងការស្វែងរកការគាំទ្រមតិ តាមប្រព័ន្ធអនឡាញរបស់មន្ត្រីវ័យក្មេងរបស់ក្រសួងនិងមន្ទីរកិច្ចការនារី ក្នុងការលើកកម្ពស់សមភាពយេនឌ័រនិងបង្កើនភាពអង់អាចដល់ស្ត្រី ។

## III. យុទ្ធសាស្ត្រ និងដំណើរការរបស់កម្មវិធី

នៅក្នុងដំណើរការអភិវឌ្ឍសមត្ថភាព ផ្តល់ការគាំទ្រ និងហ្វឹកហ្វឺនបន្ថែមដល់អ្នកចូលរួមកម្មវិធីមានសកម្មភាពសំខាន់ៗ រួមមាន៖

១. ការប៉ាន់ប្រមាណ វិភាគ និងកំណត់អំពីតម្រូវការអភិវឌ្ឍន៍សមត្ថភាពនិងលទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលរបស់មន្ត្រីវ័យក្មេងក្រសួងនិងមន្ទីរកិច្ចការនារី

២. សិក្ខាសាលាតម្រង់ទិស និងណែនាំសម្រាប់កម្មវិធីអភិវឌ្ឍន៍សមត្ថភាព។

៣. រៀបចំកម្មវិធីបណ្តុះបណ្តាលអភិវឌ្ឍន៍សមត្ថភាពឌីជីថល និងជំនាញស្តីពីការនិយាយជាសាធារណៈតាមប្រព័ន្ធអនឡាញ ដែលប្រធានបទពាក់ព័ន្ធនឹងវិស័យកិច្ចការនារី ។

៤. កម្មវិធីអនុវត្តន៍ជំនាញស្តីពី ការនិយាយជាសាធារណៈតាមប្រព័ន្ធអនឡាញ តាមរយៈការប្រកួតប្រជែងតាមទម្រង់កម្មវិធីយុវជនឆ្នើម។

## IV. វិធីសាស្ត្រ

រាល់សកម្មភាពក្នុងកម្មវិធីនេះ នឹងរៀបចំឡើងតាមប្រព័ន្ធអនឡាញ និងមានការគាំទ្របច្ចេកទេសដោយទីប្រឹក្សាបច្ចេកទេស (ភារកិច្ចសំខាន់ៗរបស់ទីប្រឹក្សាបច្ចេកទេស នឹងមានកំណត់ដោយឯកសារដោយឡែក) ។

**១. ការប៉ាន់ប្រមាណ វិភាគ និងកំណត់អំពីតម្រូវការអភិវឌ្ឍន៍សមត្ថភាពនិងលទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលរបស់មន្ត្រីវ័យក្មេងក្រសួងនិងមន្ទីរកិច្ចការនារី**

- ក្រុមការងារសម្របសម្រួលកម្មវិធី នឹងរៀបចំជាតារាងបញ្ជីសំណួរ (Google form) សម្រាប់ធ្វើការប៉ាន់ប្រមាណតម្រូវការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រី ដែលចូលរួមក្នុងកម្មវិធី។
- សិក្ខាកាមដែលនឹងត្រូវចូលរួមក្នុងកម្មវិធី (ទាំងថ្នាក់ជាតិ និងក្រោមជាតិ) ត្រូវបំពេញបញ្ជីសំណួរទាំងនេះ និងផ្ញើមកឱ្យក្រុមការងារតាមប្រព័ន្ធអនឡាញ ដើម្បីអាចឱ្យក្រុមការងារសរុបជាលទ្ធផលនៃតម្រូវការអភិវឌ្ឍសមត្ថភាពនេះ និងធ្វើការឆ្លើយតបទៅតាមតម្រូវការជាក់ស្តែង។
- តាមរយៈការគាំទ្រពីទីប្រឹក្សាឬក្រុមអ្នកជំនាញ (ដែលជ្រើសរើសដោយកម្មវិធី) ក្រុមការងារនឹងចងក្រងបញ្ជីតម្រូវការអភិវឌ្ឍន៍សមត្ថភាព និងសក្តានុពលនានា ក្នុងការលើកកម្ពស់ការចូលរួមរបស់មន្ត្រីវ័យក្មេងក្នុងប្រព័ន្ធបច្ចេកវិទ្យាឌីជីថល និងអនឡាញ ព្រមទាំងឈានទៅរៀបចំកម្មវិធីនិងប្រធានបទជាក់លាក់ សម្រាប់សកម្មភាពបន្ត ។

## ២. សិក្ខាសាលាតម្រង់ទិសនិងណែនាំពីកម្មវិធី

- សិក្ខាសាលាតម្រង់ទិស នឹងរៀបចំឡើងដើម្បីណែនាំ និងតម្រង់ទិសដល់អ្នកចូលរួមអំពីខ្លឹមសារសំខាន់ៗនៃកម្មវិធីអភិវឌ្ឍន៍សមត្ថភាព បង្ហាញអំពីសេចក្តីព្រាងតម្រូវការអភិវឌ្ឍន៍សមត្ថភាពផ្នែកឌីជីថលរបស់អ្នកចូលរួម ផ្តល់ការយល់ដឹងគន្លឹះៗអំពីចំណេះដឹងផ្នែកឌីជីថល (Digital Literacy) និងបង្ហាញនូវឧបករណ៍ឌីជីថលមួយចំនួន រួមទាំងវិធីសាស្ត្រនិងគុណតម្លៃនៃការប្រើប្រាស់ឧបករណ៍ទាំងនេះ សម្រាប់ការប្រាស្រ័យទាក់ទង និងការអនុវត្តក្នុងការងារប្រចាំថ្ងៃ ប្រកបដោយប្រសិទ្ធភាព។
- សិក្ខាសាលានេះ ក៏ជាឱកាសសម្រាប់អ្នកចូលរួមធ្វើការឆ្លុះបញ្ចាំង និងផ្តល់យោបល់ត្រឡប់អំពីតម្រូវការនិងសក្តានុពលនានា ដែលបានស្រង់និងវិភាគដោយក្រុមការងារ ។ លទ្ធផលនេះនឹងក្លាយជាធាតុចូលនិងផែនការទិចង្អុលផ្លូវដែលស៊ីជម្រៅ សម្រាប់ក្រសួងកិច្ចការនារី ប្រើប្រាស់ក្នុងរៀបចំផែនការប្រតិបត្តិនៃការធ្វើឌីជីថលភាវូនីយកម្មរបស់ស្ថាប័នផងដែរ។

## ៣. កម្មវិធីអភិវឌ្ឍសមត្ថភាព និងជំនាញស្តីពីការនិយាយជាសាធារណៈតាមប្រព័ន្ធអនឡាញ

- រៀបចំឯកសារនិងសម្ភារៈសម្រាប់ការបណ្តុះបណ្តាលនឹងត្រូវរៀបចំឡើង តាមរយៈការគាំទ្រពីអ្នកជំនាញបណ្តុះបណ្តាល និងដោយមានការពិភាក្សាជាមួយនឹងក្រុមការងារ ដោយផ្អែកតាមគោលបំណង ការរំពឹងទុក និងការរកឃើញពីការប៉ាន់ប្រមាណតម្រូវការបណ្តុះបណ្តាល។
- កម្មវិធីវគ្គបណ្តុះបណ្តាល ចំនួន៤ នឹងរៀបចំឡើងតាមរយៈប្រព័ន្ធអនឡាញ ដើម្បីផ្តល់ឱកាសដល់អ្នកចូលរួមបានអភិវឌ្ឍន៍សមត្ថភាព ស្តីពីការប្រើប្រាស់ប្រព័ន្ធអនឡាញ និងជំនាញនិយាយជាសាធារណៈប្រកបដោយឥទ្ធិពល ដែលពាក់ព័ន្ធនឹងប្រធានបទវិស័យកិច្ចការនារី ។

  ប្រធានបទសម្រាប់វគ្គបណ្តុះបណ្តាល រួមមាន៖

  ១. ចំណេះដឹងជាមូលដ្ឋានស្តីពីបច្ចេកវិទ្យាឌីជីថល និងការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព

២. បង្ហាញអំពីឧបករណ៍ឌីជីថលមួយចំនួន រួមទាំងវិធីសាស្ត្រ និងគុណតម្លៃនៃការប្រើប្រាស់ឧបករណ៍ទាំងនេះ សម្រាប់ការប្រាស្រ័យទាក់ទង និងការអនុវត្តក្នុងការងារប្រចាំថ្ងៃរបស់មន្ត្រីរាជការ

៣. ការនិយាយជាសាធារណៈ និងការជជែកពិភាក្សា តាមប្រព័ន្ធអនឡាញ

៤. ជំនាញក្នុងការស្វែងរកការគាំទ្រមតិលើការបញ្ញាបយេនឌ័រក្នុងវិស័យ

៥. ចំណេះមូលដ្ឋានស្តីពីជំនាញសិក្សាស្រាវជ្រាវ ជាពិសេសទាក់ទងនឹងវិស័យកិច្ចការនារី

៦. ការគិតបែបស៊ីជម្រៅ និងការវិភាគ។ល។

ប្រធានបទខាងលើនេះ អាចនឹងកែសម្រួលឬបន្ថែម ស្របតាមការរកឃើញក្នុងការប៉ាន់ប្រមាណពីតម្រូវការអភិវឌ្ឍសមត្ថភាពរបស់អ្នកចូលរួម និងការពិភាក្សាក្នុងសិក្ខាសាលាតម្រង់ទិស ។

- ដើម្បីឆ្លើយតបឱ្យកាន់តែមានប្រសិទ្ធភាព សិក្ខាកាមទាំងអស់នឹងទទួលបាននូវការបង្វឹកជាប្រចាំពីទីប្រឹក្សាបច្ចេកទេស និងអ្នកពាក់ព័ន្ធ ទៅតាមតម្រូវការចាំបាច់ ។

**៤. កម្មវិធីអនុវត្តន៍ជំនាញស្តីពីការនិយាយជាសាធារណៈតាមប្រព័ន្ធអនឡាញ តាមរយៈការប្រកួតប្រជែងតាមទម្រង់កម្មវិធីយុវជនវៃឆ្លាត។**

**កម្មវិធីនឹងដំណើរការជា ៤វគ្គ រួមមាន៖**

***<u>វគ្គជម្រុះលើកទី១៖ ការនិយាយជាសាធារណៈតាមអនឡាញ ឬថតជាវីដេអូ</u>***

- បេក្ខជនម្នាក់ៗមានរយៈពេល ៣នាទី ដើម្បីបកស្រាយប្រធានបទដែលចាប់បាននៅក្នុងសិក្ខាសាលាតម្រង់ទិស តាមការកំណត់ខ្លឹមសាររបស់ខ្លួន ដោយបេក្ខជននីមួយៗតម្រូវឱ្យថតវីដេអូចំនួន៣នាទី ហើយផ្ញើរមកក្រុមការងាររៀបចំកម្មវិធី។
- គណៈកម្មការនឹងមានរៀបចំជាកិច្ចប្រជុំ ដើម្បីពិនិត្យមើលវីដេអូដែលបេក្ខជនទាំងអស់ ផ្ញើរជូនដើម្បីធ្វើការដាក់ពិន្ទុ និងជម្រុះ។
- គណៈកម្មការនឹងជ្រើសរើសយកបេក្ខភាព ចំនួន១០-១៥រូប ពីវគ្គទី១នេះ ដើម្បីបន្តទៅវគ្គទី២

***<u>វគ្គជម្រុះលើកទី២៖ និយាយជាសាធារណៈតាមអនឡាញ</u>***

- បេក្ខជនម្នាក់ៗមានរយៈពេល៣នាទី ដើម្បីបកស្រាយប្រធានបទ
- អនុវត្តចំណេះដឹងពាក់ព័ន្ធប្រធានបទជាក់លាក់ ក្នុងវិស័យនីមួយៗ ដោយមានអំណះអំណាងច្បាស់លាស់។
- គណៈកម្មការនឹងជ្រើសរើសយកបេក្ខភាពចំនួន៨រូប ដើម្បីបន្តទៅវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រ

**បញ្ជាក់៖** អ្នកឈ្នះទាំង៨រូបនៅវគ្គជម្រុះលើកទី២នេះ ត្រូវចាប់ឆ្នោតជ្រើសរើសក្រុមដើម្បីត្រៀមប្រកួតស្វែងរកការគាំទ្រមតិនៅវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រ ។

***<u>វគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រ ៖ ទម្រង់ការជជែកពិភាក្សាតាមអនឡាញ</u>***

- គឺជាវគ្គតស៊ូមតិ(Debate)ដែលនៅក្នុងវគ្គនេះ បេក្ខជន ៨នាក់ ដែលជាប់ក្នុងវគ្គជម្រុះជុំទី២នឹងត្រូវបែងចែកជាពីរក្រុមដោយមួយក្រុមៗមានសមាជិក៤នាក់(១.ក្រុមស្រប និងក្រុមបដិសេធ)

ដើម្បីធ្វើការជជែកពិភាក្សាវែកញែកលើប្រធានបទដែលបានដាក់ជូន។

- ក្រុមដែលឈ្នះ និងបេក្ខជនមានវោហាស័ព្ទពីខាងក្រុមមិនឈ្នះ ១រូប នឹងត្រូវជ្រើសរើសដើម្បីប្រកួតនិយាយជាសាធារណៈនៅវគ្គផ្តាច់ព្រ័ត្រ ។
- ប្រធានបទដែលនឹងជជែកពិភាក្សា ស្តីពី"**ការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីប្រសើរជាងការជំរុញឱ្យស្ត្រីទទួលបានការអប់រំកម្រិតខ្ពស់នៅថ្នាក់ឧត្តមសិក្សា ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព**"។

*__វគ្គផ្តាច់ព្រ័ត្រ៖ ទម្រង់និយាយជាសាធារណៈ តាមអនឡាញ(Zoom Meeting or Webinar)__*

- បេក្ខជន៥រូប ដែលបានជាប់ក្នុងវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រ នឹងត្រូវ បកស្រាយលើប្រធានបទយុវជនក្នុងបរិការណ៍កូវីដ-១៩
- ម្នាក់ៗមានរយៈពេល៥នាទីដើម្បីបកស្រាយ។
- ក្នុងវគ្គនេះ យុវជនចំនួន៣ រូបនឹងត្រូវជ្រើសរើសជាជ័យលាភី លេខ ១ លេខ ២ និងលេខ ៣ ក្នុងកម្មវិធីប្រកួត**យុវជនវៃឆ្លាតក្រសួងកិច្ចការនារី ក្នុងយុគសម័យឌីជីថល ២០២១។**

## V. **រយៈពេលកម្មវិធី**

កម្មវិធីនេះមានរយៈពេល៣ខែ ក្នុងការរៀបចំ និងអនុវត្តន៍ ដោយអ្នកចូលរួមតម្រូវឱ្យមានឆន្ទៈ និងពេលវេលាគ្រប់គ្រាន់ក្នុងការចូលរួមក្នុងសកម្មភាពនីមួយៗ។

| ល.រ | សកម្មភាព | កាលបរិច្ឆេទ |
|---|---|---|
| ១ | ការប៉ាន់ប្រមាណពីតម្រូវការអភិវឌ្ឍសមត្ថភាព | សប្តាហ៍ទី១-ទី៤ ខែឧសភា |
| ២ | សិក្ខាសាលាតម្រង់ទិសនិងណែនាំពីកម្មវិធី | សប្តាហ៍ទី១ ខែមិថុនា |
| ៣ | វគ្គបណ្តុះបណ្តាល (៤ វគ្គ) និងវគ្គបង្វឹក (តាមតម្រូវការជាក់ស្តែង) | សប្តាហ៍ទី៤មិថុនា-សប្តាហ៍ទី២ សីហា |
| ៤ | វគ្គជម្រុះលើកទីមួយ | សប្តាហ៍ទី ២ ខែកញ្ញា |
| ៥ | វគ្គជម្រុះលើកទីពីរ | សប្តាហ៍ទី៤ ខែកញ្ញា |
| ៦ | វគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រ | សប្តាហ៍ទី៣ ខែតុលា |
| ៧ | វគ្គផ្តាច់ព្រ័ត្រ និងការប្រគល់រង្វាន់ជ័យលាភី | សប្តាហ៍ទី៤ ខែតុលា |

## VI. **លក្ខខណ្ឌចូលរួម**

ដើម្បីធានាថាកម្មវិធីផ្តល់ឱកាស និងអភិវឌ្ឍន៍សមត្ថភាពដល់មន្ត្រីគ្រប់រូបកម្មវិធី នឹងធ្វើការផ្សព្វផ្សាយពីកម្មវិធីជ្រើសរើសមន្ត្រីនៅតាមនាយកដ្ឋាន ក្រសួងកិច្ចការនារី អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងមន្ទីរកិច្ចការនារីរាជធានី ខេត្ត និងតម្រូវឱ្យធ្វើការចុះឈ្មោះតាមប្រព័ន្ធអនឡាញ។

តាមរយៈការណែនាំពី**លោកជំទាវរដ្ឋមន្ត្រី** កម្មវិធីតម្រូវឱ្យថ្នាក់ដឹកនាំនាយកដ្ឋាននិងអង្គភាពនីមួយៗចាត់មន្ត្រីចូលរួមក្នុងកម្មវិធី ជាការកំណត់ និងសម្រាប់អ្នកដែលមានបំណាង់ចូលរួមមួយចំនួនទៀតតាមរយៈការជ្រើសរើស និងសម្រេចរបស់ក្រុមការងារ ។

- **លក្ខន្តិកនៃការជ្រើសរើសអ្នកចូលរួម៖**

**១. តើនរណាអាចចូលរួមកម្មវិធីនេះបាន?**

បេក្ខជនចំនួនប្រមាណ៨០រូបនៃកម្មវិធី ត្រូវមានលក្ខត្តិក:ដូចខាងក្រោម៖

- អាយុចាប់ពី ១៨ឆ្នាំ ទៅ៣៥ ឆ្នាំ
- ជាមន្ត្រីក្របខណ្ឌឬមន្ត្រីកិច្ចសន្យារបស់ក្រសួងកិច្ចការនារី មកពីនាយកដ្ឋានទាំង១១ (៣ក្នុងមួយអង្គភាព) អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (៥រូប) មន្ត្រីខុទ្ទកាល័យរដ្ឋមន្ត្រី (២រូប) និងមន្ត្រីមកពីមន្ទីរកិច្ចការនារីរាជធានី ខេត្ត (២៥រូប) ដែលមានឆន្ទៈក្នុងការអភិវឌ្ឍសមត្ថភាពរបស់ខ្លួនលើជំនាញនិយាយជាសាធារណៈតាមប្រព័ន្ធអនឡាញ និងស្របតាមការចាត់តាំងរបស់នាយកដ្ឋាន ឬអង្គភាពខ្លួន ។
- អ្នកមានការប្តេជ្ញាចិត្តខ្ពស់ និងបំណង់ចង់បង្កើនការយល់ដឹងផ្នែកឌីជីថល។

## VII. គណៈកម្មការដាក់ពិន្ទុ មាន០៥រូប

- អគ្គនាយក ទាំង០៣ ក្រោមចំណុះក្រសួងកិច្ចការនារី
- តំណាងមកពីដៃគូអភិវឌ្ឍន៍/ឬតំណាងមកពីវិស័យឯកជន ១រូប
- គ្រូបណ្តុះបណ្តាល ១រូប

## VIII. ដៃគូគាំទ្រ

តាមរយៈក្របខណ្ឌកម្មវិធីដំណើរឆ្ពោះទៅមុខដើម្បីសមភាពយេនឌ័រ(LWGE) ក្រសួងកិច្ចការនារី នឹងធ្វើចលនាប្រភពធនធានក្នុងការអនុវត្តកម្មវិធីនេះ ជាមួយដៃគូដែលមានសក្តានុពលនានា រួមមាន៖ DFAT/ACCESS, UNICEF, UNFPA, Recoftc, Cambodia Development Center (CDC), Konrad-Adenauer-Stiftung Cambodia និងដៃគូអភិវឌ្ឍន៍នានារួមមាន វិស័យឯកជន។

ដៃគូដែលគាំទ្រនិងឧបត្ថម្ភក្នុងកម្មវិធីនេះ នឹងត្រូវបានអញ្ជើញចូលរួមក្នុងសិក្ខាសាលាតម្រង់ទិស និងបើកកម្មវិធី កម្មវិធីបិទនិងសកម្មភាពនានារបស់កម្មវិធី ព្រមទាំងស្នើក្នុងការដាក់ឈ្មោះ/Logo របស់ដៃគូនៅក្នុងលិខិតផ្សព្វផ្សាយរបស់កម្មវិធី និងវិញ្ញាបនបត្របញ្ជាក់ការសិក្សារបស់អ្នកចូលរួមផងដែរ។

## IX. អ្នកចូលរួម នឹងទទួលបានពីកម្មវិធី?

- សមត្ថភាពក្នុងការប្រើប្រាស់ប្រព័ន្ធឌីជីថលការនិយាយជាសាធារណៈតាមប្រព័ន្ធអនឡាញកាន់តែមានប្រសិទ្ធភាព និងអាចយកទៅប្រើប្រាស់បាននៅក្នុងបរិបទការងារតាមបែបគន្លងថ្មី
- ប័ណ្ណសរសើរអំពីការចូលរួមក្នុងកម្មវិធីដល់គ្រប់បេក្ខជនទាំងអស់
- មេដាយសម្រាប់អ្នកលេខ ១ លេខ២ និងលេខ ៣
- ពានសម្រាប់យុវជនវៃឆ្លាត យុគសម័យឌីជីថល ២០២១ ដល់អ្នកលេខ១
- វត្ថុអនុស្សាវរីយ៍ ដែលផ្តល់ដោយអ្នកគាំទ្រ និងឧបត្ថម្ភកម្មវិធី
- រង្វាន់លើកទឹកចិត្តផ្សេងៗ (Surprised Gift) សម្រាប់អ្នកនៅលំដាប់ ១ ដល់៣។

## X. ការដាក់ពាក្យ៖ សូមដាក់ពាក្យឱ្យបានមុន២៤ ម៉ោងមុនបិទទទួលពាក្យ។

- សម្រាប់មន្ត្រីនៅតាមនាយកដ្ឋាន និងអង្គភាពនៅថ្នាក់ក្រសួង អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មន្ត្រីមន្ទីរកិច្ចការនារី សូមបំពេញឈ្មោះក្នុងតំណរភ្ជាប់តាមប្រព័ន្ធអនឡាញ https://docs.google.com/forms/d/e/1FAIpQLSeSA36sXlfWVciIfB9zCSk5xci7S5-e2fj0sBnHchApk97pxA/viewform?usp=sf_link
- សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង តាមរយៈអ៊ីម៉ែល ឬទូរស័ព្ទខាងក្រោម៖ aunchansreylaek@gmail.com Tel: 092 392 172